# ព្រះរាជក្រម

នស/រកម/០៣១៥/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា
ចូល លេខ ... ថ្ងៃទី ... ឆ្នាំ២០១៥ ម៉ោង ...
បញ្ជូនទៅ ...

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៦ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៣/០០១/២០១៥ កបធ.ច ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅនៃ
# គណៈកម្មាធិការជាតិ
# រៀបចំការបោះឆ្នោត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីរៀបចំ ចាត់ចែង និងគ្រប់គ្រងការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់ ។

**មាត្រា ២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានឈ្មោះជាអក្សរកាត់ "គ.ជ.ប" ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ដើម្បីអនុវត្តការងាររបស់ខ្លួន ។

**មាត្រា ៣.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ។

សមាជិកទាំងឡាយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសមាជិក នៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវមានជំហរអព្យាក្រឹតឥតលម្អៀងក្នុងការអនុវត្តការងារបោះឆ្នោត ។

# ជំពូកទី ២
# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ផ្នែកទី ១
## ការរៀបចំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មាត្រា ៤.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាព ០៩ (ប្រាំបួន) រូប ដែលរួមមាន ៖

- ប្រធាន 01 (មួយ) រូប

-អនុប្រធាន ០១ (មួយ) រូប

-សមាជិក ០៧ (ប្រាំពីរ) រូប ។

**មាត្រា ៥.-**

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនខ្មែរទាំងពីរភេទ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរតែមួយគត់ ក្នុងពេលបំពេញការងារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-មានអាយុយ៉ាងតិច ៣៥ (សាមសិបប្រាំ) ឆ្នាំ គិតដល់ថ្ងៃតែងតាំង

-មានសិទ្ធិបោះឆ្នោត

-មានសញ្ញាបត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ

-មានបទពិសោធន៍ការងារយ៉ាងតិច ១០ (ដប់) ឆ្នាំ

-មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៣ របស់ប្រធាន អនុប្រធានគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ។

**មាត្រា ៦.-**

សមាសភាពទាំង ០៩ (ប្រាំបួន) រូប នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសដោយ ៖

-០៤ (បួន) រូប ជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល

-០៤ (បួន) រូប ជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភា ដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និង

-០១ (មួយ) រូបទៀត ជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា ។

ផ្អែកតាមគោលការណ៍ខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវធ្វើការសម្របសម្រួលជាមួយគណបក្សនយោបាយទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីប្រកាសជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសាធារណៈ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ថ្ងៃ ។ បន្ទាប់មក គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវសម្របសម្រួលជាមួយគណបក្សទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បី

ពិនិត្យជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពីក្នុងចំណោមបេក្ខជនដែលបានដាក់ពាក្យស្នើសុំ ដោយផ្អែកតាមលក្ខណសម្បត្តិ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

បែបបទ និងនីតិវិធីនៃការជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។

ផ្អែកលើសមាសភាពដែលបានជ្រើសរើសខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវរៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីរដ្ឋសភាថ្មីចូលកាន់តំណែង ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។

## មាត្រា ៧.-

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានអាណត្តិ ០៥ (ប្រាំ) ឆ្នាំ ហើយត្រូវផុតអាណត្តិនៅពេលសមាសភាពថ្មីចូលកាន់តំណែង ។

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ច ដើម្បីចាត់ចែងរៀបចំបោះឆ្នោតស្របតាមច្បាប់ជាធរមាន ។

## មាត្រា ៨.-

មុខងារជាប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានព្យួរសិទ្ធិបោះឆ្នោតជាបណ្ដោះអាសន្ន រហូតដល់ថ្ងៃបញ្ចប់មុខតំណែង ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាសមាជិកនៃគណបក្សនយោបាយ ត្រូវសុំលាលែងពីគណបក្សនយោបាយ ហើយអាចចូលជាសមាជិកគណបក្សនយោបាយវិញបាន ក្នុងរយៈពេលយ៉ាងតិច ០២ (ពីរ) ឆ្នាំ បន្ទាប់ពីបញ្ចប់អាណត្តិការងារ ឬបាត់បង់មុខតំណែង ឬត្រូវបានបណ្ដេញចេញ ដូចមានចែងក្នុងមាត្រា ៧ មាត្រា ៩ និងមាត្រា ១០ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាសមាជិក ឬ/និងជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងក្រុមហ៊ុនពាណិជ្ជកម្ម ឬ/និងមន្ត្រីរាជការ ត្រូវសុំលាលែងពីអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងក្រុមហ៊ុនពាណិជ្ជកម្ម ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់អាណត្តិ ។

**មាត្រា ៩.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបាត់បង់មុខតំណែងក្នុងករណីណាមួយ ដូចខាងក្រោម៖

-សាមីខ្លួន ទទួលមរណភាព

-សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ

-សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួន ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

**មាត្រា ១០.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានគណនេយ្យភាពចំពោះមុខរដ្ឋសភា ។

ការសម្រេចបណ្តេញចេញពីប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសមត្ថកិច្ចរបស់រដ្ឋសភា ។

**មាត្រា ១១.-**

ក្នុងករណីដែលមានប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបាត់បង់ពីមុខតំណែង គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវសម្របសម្រួលជាមួយគណបក្សនយោបាយពាក់ព័ន្ធ ដើម្បីប្រកាសជ្រើសរើសជាសាធារណៈនូវបេក្ខភាពបេក្ខជនដែលត្រូវជំនួសមុខតំណែងដែលទំនេរ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ ។

បន្ទាប់មក គណបក្សពាក់ព័ន្ធត្រូវជ្រើសរើសសមាសភាពថ្មីពីក្នុងចំណោមអ្នកដែលបានដាក់ពាក្យក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ដាក់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារៀបចំដាក់សមាសភាពថ្មីនេះ ជូនរដ្ឋសភាបោះឆ្នោតទុកចិត្ត តាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្នុងករណីដែលមានការរៀបចំបោះឆ្នោត និងយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ ក្នុងករណី ដែលគ្មានការរៀបចំបោះឆ្នោត ។

ករណីគណបក្សនយោបាយពាក់ព័ន្ធខកខានមិនបានជ្រើសរើសសមាសភាពថ្មីតាមការកំណត់ខាងលើ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវធ្វើការជ្រើសរើសបេក្ខភាពបេក្ខជន ដែលត្រូវជំនួសមុខតំណែងទំនេរនោះ ដោយផ្អែកតាមលក្ខណសម្បត្តិ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ពីក្នុងចំណោមអ្នកដែលបានដាក់ពាក្យ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាពក្នុងរយៈពេលយ៉ាងតិច ០២ (ពីរ) ថ្ងៃ ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ក្នុងរយៈពេលយ៉ាងយូរ ០២ (ពីរ) ថ្ងៃ ក្នុងករណីដែលមានការរៀបចំបោះឆ្នោត និងយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្នុងករណីដែលគ្មានការរៀបចំបោះឆ្នោត ។

បែបបទ នីតិវិធីនៃការដាក់ពាក្យ ការជ្រើសរើស និងការរៀបចំបញ្ជីបេក្ខជនដាក់ជូនរដ្ឋសភាត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។

ប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានទទួលការតែងតាំងជំនួសកន្លែងទំនេរនោះ ត្រូវធ្វើសច្ចាប្រណិធានចូលកាន់តំណែងភ្លាម ។

ប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលត្រូវបានតែងតាំងជំនួសកន្លែងទំនេរនោះ មានអាណត្តិត្រឹមអាណត្តិដែលនៅសល់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១២.-**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើឧបនាយករដ្ឋមន្ត្រី ។

អនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើទេសរដ្ឋមន្ត្រី ។

សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើរដ្ឋមន្ត្រី ។

**មាត្រា ១៣.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តតួនាទីរបស់ខ្លួនដោយមិនលម្អៀង ដោយឈរលើគោលការណ៍គោរពច្បាប់ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ការបំភិតបំភ័យ ឬការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីបុគ្គល ឬស្ថាប័នណាមួយឡើយ ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបានការធានាការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងគ្រួសារ ក្នុងករណីចាំបាច់ តាមសំណូមពររបស់សាមីខ្លួន ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនត្រូវទទួលខុស

ត្រូវខាងបទព្រហ្មទណ្ឌ ឬបទរដ្ឋប្បវេណីណាមួយ ចំពោះការសម្រេចដែលបានធ្វើក្នុងក្របខ័ណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនឡើយ ។

## ផ្នែកទី ២
## ការរៀបចំគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

### មាត្រា ១៤.-

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតមានសមាសភាព ដូចខាងក្រោម ៖

| | |
|---|---|
| -ប្រធាន | ០១ (មួយ) រូប |
| -អនុប្រធាន | ០១ (មួយ) រូប |
| -សមាជិក | ០៣ (បី) ឬ ០៥ (ប្រាំ) រូប ។ |

ចំនួនជាក់ស្តែងនៃសមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត តាមរាជធានី ខេត្តនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

### មាត្រា ១៥.-

ប្រធានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធាននាយកដ្ឋាននៃក្រសួង ស្ថាប័ន ។

អនុប្រធានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធាននាយកដ្ឋាននៃក្រសួង ស្ថាប័ន ។

សមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធានការិយាល័យនៃក្រសួង ស្ថាប័ន ។

### មាត្រា ១៦.-

សមាសភាពគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងរាជធានី ខេត្តដែលមានសិទ្ធិបោះឆ្នោត លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ១៧.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់តាំងគណៈកម្មការមួយ ដើម្បីធ្វើការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ។

បែបបទ និងនីតិវិធីជាក់ស្ដែងនៃដំណើរការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៨.–**

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៩.–**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែន រដ្ឋាភិបាល សមាគម សហជីព ឬ/និងមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំង ត្រូវសុំលាលែងពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់ភារកិច្ច ។

**មាត្រា ២០.–**

ប្រធាន អនុប្រធាន ឬសមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតត្រូវបាត់បង់ពីមុខតំណែងក្នុងករណីណាមួយ ដូចខាងក្រោម ៖

-សាមីខ្លួន ទទួលមរណភាព

-សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ

-សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័ន មានសមត្ថកិច្ច

–សាមីខ្លួន ត្រូវផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

**មាត្រា ២១.–**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតត្រូវមានឯករាជ្យភាពចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិសម្រេចបណ្តេញប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតណាមួយ ក្នុងករណីប្រព្រឹត្តផ្ទុយពីច្បាប់ស្តីពីការបោះឆ្នោតជាធរមាន បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោត ឬក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត ។

**មាត្រា ២២.-**

សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការរាជធានី ខេត្ត ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់ ៦០ (ហុកសិប) ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់ ៣០ (សាមសិប) ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

**មាត្រា ២៣.-**

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវមានលេខាធិការដ្ឋានមួយ ជាជំនួយការ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៤.-**

ក្នុងចន្លោះពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ឲ្យមន្ត្រីលេខាធិការដ្ឋានមួយចំនួន បន្តការងារ ដើម្បីធានានិរន្តរភាពនៃការងារបោះឆ្នោតតាមរាជធានី ខេត្តនីមួយៗ ។

**មាត្រា ២៥.-**

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតមានតួនាទី ភារកិច្ចដូចតទៅ ៖

១-អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជា នីតិវិធីនៃការបោះឆ្នោត និងលិខិតបទដ្ឋាននានាដែលបានអនុញ្ញាត ឬតម្រូវឲ្យអនុវត្ត ។

២-អនុវត្តភារកិច្ច និងសិទ្ធិដទៃទៀតដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឲ្យ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ៣
## ការរៀបចំគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

### មាត្រា ២៦.-

គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតមានសមាសភាព ដូចខាងក្រោម៖

-ប្រធាន ០១ (មួយ) រូប

-អនុប្រធាន ០១ (មួយ) រូប

-សមាជិក ០៣ (បី) ឬ ០៥ (ប្រាំ) រូប ។

ចំនួនជាក់ស្តែងនៃសមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

### មាត្រា ២៧.-

សមាសភាពគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ។

### មាត្រា ២៨.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់តាំងគណៈកម្មការមួយ ដើម្បីធ្វើការជ្រើសរើសសមាសភាពគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ។

បែបបទ និងនីតិវិធីជាក់ស្តែងនៃដំណើរការជ្រើសរើសសមាសភាពគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

### មាត្រា ២៩.-

គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត តាមសំណើរបស់គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដោយផ្អែកលើលទ្ធផលនៃការជ្រើសរើសសមាសភាពគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតរបស់គណៈកម្មការជ្រើសរើស ដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៣០.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំង ត្រូវសុំលាលែងពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់ភារកិច្ច ។

**មាត្រា ៣១.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវបាត់បង់ពីមុខតំណែងក្នុងករណីណាមួយ ដូចខាងក្រោម ៖

-សាមីខ្លួន ទទួលមរណភាព

-សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ

-សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមាន សមត្ថកិច្ច

-សាមីខ្លួន ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

**មាត្រា ៣២.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវមានគណនេយ្យភាពតាមឋានានុក្រមចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិសម្រេចបណ្តេញប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតណាមួយ ក្នុងករណីប្រព្រឹត្តផ្ទុយពីច្បាប់ស្តីពីការបោះឆ្នោតជាធរមាន បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោត ឬក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចចេញសេចក្តីសម្រេចធ្វើប្រតិភូកម្មអំណាចជូនគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត តាមការចាំបាច់ ដើម្បីអនុវត្តបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រានេះ ។

**មាត្រា ៣៣.-**

គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតមានតួនាទីភារកិច្ច ដូចតទៅ ៖

១-អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជា នីតិវិធីនៃការបោះឆ្នោត និងលិខិតបទដ្ឋាននានាដែលបានអនុញ្ញាត ឬតម្រូវឲ្យអនុវត្ត ។

២-អនុវត្តភារកិច្ច និងសិទ្ធិដទៃទៀតដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឲ្យ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ផ្នែកទី ៤
# ការរៀបចំគណៈកម្មការការិយាល័យបោះឆ្នោត

## មាត្រា ៣៤.-

គណៈកម្មការការិយាល័យបោះឆ្នោតនីមួយៗ មានសមាសភាព ដូចខាងក្រោម ៖

-ប្រធាន 01 (មួយ) រូប

-អនុប្រធាន 01 (មួយ) រូប

-លេខាធិការ 01 (មួយ) រូប

-សមាជិក 0៣ (បី) រូប ។

## មាត្រា ៣៥.-

សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែង តែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ។

## មាត្រា ៣៦.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់តាំងគណៈកម្មការមួយ ដើម្បីធ្វើការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព ។

បែបបទ និងនីតិវិធីជាក់ស្តែងនៃដំណើរការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## មាត្រា ៣៧.-

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមសំណើរបស់គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដោយផ្អែកលើលទ្ធផលនៃការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោតរបស់គណៈកម្មការជ្រើសរើស ដូចមានចែងក្នុងមាត្រា ៣៦ នៃច្បាប់នេះ ។

## មាត្រា ៣៨.-

ប្រធាន អនុប្រធាន លេខាធិការ និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ឬ/និងមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំង ត្រូវសុំលាលែងជាបណ្ដោះអាសន្នពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំច្បាប់ឈប់សម្រាកពីការងារ រហូតដល់ថ្ងៃចប់ភារកិច្ច ។

**មាត្រា ៣៩.–**

ប្រធាន អនុប្រធាន លេខាធិការ និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវបាត់បង់ពីមុខតំណែងក្នុងករណីណាមួយ ដូចខាងក្រោម ៖

-សាមីខ្លួន ទទួលមរណភាព

-សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ

-សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួន ត្រូវផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

**មាត្រា ៤០.–**

ប្រធាន អនុប្រធាន លេខាធិការ និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតត្រូវមានគណនេយ្យភាពតាមឋានានុក្រម ចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិសម្រេចបណ្ដេញប្រធាន អនុប្រធាន លេខាធិការ និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតណាមួយ ក្នុងករណីប្រព្រឹត្តផ្ទុយពីច្បាប់ស្ដីពីការបោះឆ្នោតជាធរមាន បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ឬក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចចេញសេចក្ដីសម្រេចធ្វើប្រតិភូកម្មអំណាចជូនគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត តាមការចាំបាច់ ដើម្បីអនុវត្តបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រានេះ ។

**មាត្រា ៤១.–**

គណៈកម្មការការិយាល័យបោះឆ្នោតមានតួនាទីភារកិច្ច ដូចតទៅ ៖

១-អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជា នីតិវិធីនៃការបោះឆ្នោត និងលិខិតបទដ្ឋាននានាដែលបានអនុញ្ញាត ឬតម្រូវឲ្យអនុវត្ត ។

២-អនុវត្តភារកិច្ច និងសិទ្ធិដទៃទៀតដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឲ្យ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

### ផ្នែកទី ១
### សមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មាត្រា ៤២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមត្ថកិច្ចក្នុងការធ្វើផែនការរៀបចំ និងចាត់ចែងការបោះឆ្នោតក្នុងទូទាំងប្រទេស ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិពេញលេញក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់នេះ ច្បាប់ស្តីពីការបោះឆ្នោតជាធរមាន បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោត ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

សិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវទាក់ទងនឹងផែនការកម្ម ការរៀបចំ ការចាត់ចែង និងត្រួតពិនិត្យការបោះឆ្នោត មានដូចតទៅ ៖

១-ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតាមវិធីជ្រើសរើសឆ្នោត ដោយសម្ងាត់ ។

២-រៀបចំគម្រោងផែនការការងារ ថវិកា និងសម្ភារបម្រើឲ្យការបោះឆ្នោត និងផ្សព្វផ្សាយប្រតិទិននៃការបោះឆ្នោត ។

៣-តែងតាំងគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ។

៤-ធ្វើបទបញ្ញា នីតិវិធី និងសេចក្តីណែនាំនានាសម្រាប់ដំណើរការបោះឆ្នោត ក្នុងក្របខ័ណ្ឌនៃច្បាប់ជាធរមាន ។

៥-លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត ។

៦-ត្រួតពិនិត្យការងាររបស់គណៈកម្មការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៧-កំណត់ព្រំដែនការិយាល័យបោះឆ្នោត ។

៨-ចេញសេចក្តីសម្រេចកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ។

៩-ផលិត និងបែងចែកសម្ភារ បរិក្ខារ បំរើឲ្យការងារបោះឆ្នោត ។

១០-ជ្រើសរើស និងតែងតាំងមន្ត្រីចុះជួយពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមច្បាប់ បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

១១- រៀបចំបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

១២-ពិនិត្យ និងផ្តល់សុពលភាព បញ្ជីបោះឆ្នោត ។

១៣-ទទួល និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ស្របតាមច្បាប់បោះឆ្នោតជាធរមាន ។

១៤-គ្រប់គ្រង និងត្រួតពិនិត្យការប្រព្រឹត្តទៅនៃការឃោសនាបោះឆ្នោត ។

១៥-រៀបចំ និងចាត់ចែងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផល ។

១៦-ដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬផ្តល់សិទ្ធិបោះឆ្នោតឡើងវិញ ។

ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬលុបចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ។

លុបបេក្ខភាពរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ឬទទួលស្គាល់បេក្ខភាពឈរឈ្មោះបោះឆ្នោតឡើងវិញ ។

១៧-ត្រួតពិនិត្យចំណូល និងចំណាយ ក្នុងរយៈពេលឃោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយ ។

១៨-ចាត់វិធានការ និងសម្របសម្រួល ដើម្បីឲ្យមានការប្រើប្រាស់ប្រព័ន្ធឃោសនាសាធារណៈតាមគោលការណ៍ស្មើភាព និងសមធម៌ ។

១៩-ផ្តល់ព័ត៌មាន ទិន្នន័យ និងស្ថិតិអំពីដំណើរការបោះឆ្នោតដល់គណបក្សនយោបាយ និងបេក្ខជន និងទទួលសំណើនានាទាក់ទងនឹងការងារបោះឆ្នោត ។

ធានាឲ្យមានការផ្លាស់ប្តូរព័ត៌មាន និងការសម្របសម្រួលជាប្រចាំ អំពីកិច្ចដំណើរការបោះឆ្នោតរវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាមួយគណបក្សនយោបាយ បេក្ខជន និងអ្នកដែលពាក់ព័ន្ធនានា ។

២០-ផលិតឯកសារផ្សព្វផ្សាយ អំពីការងារបោះឆ្នោត ។

២១-លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីការងារបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងដោយមធ្យោបាយផ្សេងៗទៀត ។

២២-រៀបចំឯកសារ កម្មវិធី និងបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុករៀបចំការបោះឆ្នោត ។

២៣-ពិនិត្យសម្រេច និងចេញប័ណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ។

២៤-ត្រួតពិនិត្យ ដើម្បីធានាភាពត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២៥-សម្រេចដោយបើកសវនាការជាសាធារណៈលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត ស្របតាមច្បាប់ បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោត លើកលែងតែបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ ។

២៦-បង្ការ និងត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត ។

២៧-រៀបចំគណៈកម្មការដើម្បីបំផ្លាញសន្លឹកឆ្នោត ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រតាមអាណត្តិនីមួយៗ បន្ទាប់ពីបានរក្សាទុកប្រកបដោយសុវត្ថិភាពនូវសន្លឹកឆ្នោតទាំងនោះរយៈពេល ០៦ (ប្រាំមួយ) ឆ្នាំ និងសន្លឹកឆ្នោតដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តាមអាណត្តិនីមួយៗ បន្ទាប់ពីបានរក្សាទុកប្រកបដោយសុវត្ថិភាពនូវសន្លឹកឆ្នោតទាំងនោះរយៈពេល ០៣ (បី) ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោតតាមអាណត្តិនីមួយៗ ។

ដំណើរការនៃការបំផ្លាញសន្លឹកឆ្នោតខាងលើនេះ ត្រូវធ្វើឡើងប្រកបដោយលក្ខណៈបើកចំហ និងមានការចូលរួមពីគណបក្សនយោបាយដែលពាក់ព័ន្ធ ។

២៨-អនុវត្តការងារដទៃទៀតតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា ៤៣.-**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ ៖

១-ធានាថា សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងអស់ ត្រូវប្រតិបត្តិតាមច្បាប់ បទបញ្ជាផ្ទៃក្នុងរបស់ខ្លួន បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ព្រមទាំងក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត ។

២-កោះអញ្ជើញ និងដឹកនាំរាល់ការប្រជុំសាមញ្ញ និងការប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

៣-ជាតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅក្នុងការទំនាក់ទំនងជាមួយព្រះមហាក្សត្រ ស្ថាប័ននានា អង្គការជាតិ និងអង្គការអន្តរជាតិ ។

៤-ជូនរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅរដ្ឋសភា និងព្រឹទ្ធសភា ។

៥-ចុះហត្ថលេខាលើគ្រប់ឯកសារផ្លូវការ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៤៤.-**

អនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជួយធ្វើការប្រធានទៅតាមការបែងចែកភារកិច្ចពីប្រធាន ។ កាលបើប្រធានអវត្តមាន ឬមកធ្វើការពុំបាន អនុប្រធានធ្វើការជួសប្រធាន ក្នុងឋានៈជាប្រធានស្តីទីតាមរយៈលិខិតផ្ទេរសិទ្ធិ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៤៥.-**

សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលភារកិច្ចតាមការកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង និងតាមការប្រគល់ភារកិច្ចពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៤៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចចេញសេចក្ដីសម្រេចប្រគល់សិទ្ធិរបស់ខ្លួនដល់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការការិយាល័យបោះឆ្នោត និងមន្ត្រី ឬភ្នាក់ងារបម្រើការងារបោះឆ្នោត ដើម្បីអនុវត្តការងារបោះឆ្នោត ។

**មាត្រា ៤៧.-**

ប្រាក់បំណាច់ និងប្រាក់កម្រៃសម្រាប់សមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ផ្នែកទី ២
## របៀបរបបការងាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មាត្រា ៤៨.-**

របៀបរបបធ្វើការងាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងដែលរៀបចំ និងអនុម័តដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៤៩.-**

បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងច្បាប់ស្ដីពីការបោះឆ្នោតជាធរមាន បន្ទាប់ពីចូលកាន់តំណែង ។

**មាត្រា ៥០.-**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាអ្នកកោះប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីដែលសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនបានចូលរួមប្រជុំ ឬអវត្តមានដោយគ្មានមូលហេតុតាមការកោះប្រជុំចាប់ពី ០៣ (បី) ដងឡើងទៅ សមាជិកនោះ ត្រូវចាត់ទុកថាបោះបង់មុខតំណែង ។

សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមួយភាគបី (១/៣) មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរ ដោយភ្ជាប់ជាមួយរបៀបវារៈ ឬកម្មវត្ថុជាក់លាក់ទៅប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីកោះប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយប្រធានគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកោះប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ការប្រជុំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចយកជាការបាន លុះត្រាតែមាន ៖

-កូរ៉ុមពីរភាគបី (២/៣) នៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូលសម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឲ្យយកមតិភាគច្រើន ពីរភាគបី (២/៣) នៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។

-កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូលសម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឲ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុម័តសម្រេចបទបញ្ជាផ្ទៃក្នុង និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ដោយសំឡេងពីរភាគបី (២/៣) នៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។ ករណីមិនមានកូរ៉ុម ឬ/និងសំឡេងគ្រប់ចំនួនសម្រាប់អនុម័តតាមមតិភាគច្រើន ពីរភាគបី (២/៣) នៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការកោះប្រជុំជាលើកទី ២ នៅថ្ងៃបន្ទាប់ជាបន្ទាន់ ហើយកូរ៉ុម និងសំឡេងសម្រាប់អនុម័ត ត្រូវមានចំនួនភាគច្រើនដាច់ខាតនៃសមាជិកគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។

ក្រៅពីបទបញ្ជាផ្ទៃក្នុង និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវអនុម័តសម្រេច ដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។

ករណីមានសំឡេងស្មើគ្នាក្នុងការអនុម័តលើបញ្ហាណាមួយ សំឡេងរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឧត្តមានុភាព ។

ក្នុងករណីដំណើរការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជាប់គាំងដោយសារមិនមានកូរ៉ុម ឬមិនមានសំឡេងគ្រប់គ្រាន់ ដើម្បីអនុម័តបញ្ហាណាមួយ រដ្ឋសភាត្រូវធ្វើការសម្រេចលើសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានបញ្ហានោះ ហើយត្រូវរៀបចំសមាសភាពថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៥១.-**

រាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីការធ្វើសេចក្តីសម្រេច ។

## ផ្នែកទី ៣
## អគ្គលេខាធិការដ្ឋាន

**មាត្រា ៥២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

អគ្គលេខាធិការ អគ្គលេខាធិការរង និងមន្ត្រី បុគ្គលិកទាំងអស់ ត្រូវមានគណនេយ្យភាពតាមឋានានុក្រមចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៥៣.-**

អគ្គលេខាធិការដ្ឋានត្រូវដឹកនាំដោយអគ្គលេខាធិការមួយ (០១) រូប និងអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ។

**មាត្រា ៥៤.-**

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរតែមួយគត់ ក្នុងរយៈពេលបំពេញការងារ

-មានអាយុយ៉ាងតិច ៣០ (សាមសិប) ឆ្នាំ គិតដល់ថ្ងៃតែងតាំង

-មានសិទ្ធិបោះឆ្នោត

-មានសញ្ញាបត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ

-មានបទពិសោធន៍ការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ

-មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៣ របស់ប្រធាន អនុប្រធានគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ។

**មាត្រា ៥៥.-**

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ទាប់ពីបានយោបល់យល់ស្របតាមសម្លេងភាគច្រើនដាច់ខាតនៃសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។

អគ្គលេខាធិការត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ។

អគ្គលេខាធិការរងត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុរដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មន្ត្រី បុគ្គលិកនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងនៃលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត គឺជាមន្ត្រី បុគ្គលិក ស្ថិតក្នុងក្របខ័ណ្ឌនៃលក្ខន្តិកៈដោយឡែកមួយ ដែលកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ទាប់ពីមានយោបល់ឯកភាពពីក្រសួងមុខងារសាធារណៈ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបម្រើការងារតាមការចាំបាច់ ។

**មាត្រា ៥៦.–**

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវបាត់បង់មុខតំណែង ក្នុងករណីណាមួយ ដូចខាងក្រោម ៖

-សាមីខ្លួន ទទួលមរណភាព

-សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ

-សាមីខ្លួន បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួន ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

**មាត្រា ៥៧.–**

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី ៤
## ថវិការបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មាត្រា ៥៨.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វយ័តសម្រាប់ដំណើរការ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ចែង និងប្រើប្រាស់ថវិកាសម្រាប់កិច្ចការបោះឆ្នោត ប្រកបដោយតម្លាភាព សុចរិតភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

**មាត្រា ៥៩.–**

ត្រូវបានបង្កើតគណនីពិសេសរបស់រតនាគារជាតិ ជាគណនីមូលនិធិទាយជ្ជទានការបោះឆ្នោត សម្រាប់ឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យកទៅចាត់ចែងក្នុងកិច្ចការបោះឆ្នោត ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

មូលនិធិទាយជ្ជទានការបោះឆ្នោត ដែលបានមកពីវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ជំនួយរបស់រដ្ឋាភិបាលបរទេស អង្គការអន្តរជាតិនានា អំណោយពីសប្បុរសជន អំណោយពីអង្គការក្រៅរដ្ឋាភិបាល និងចំណូលស្របច្បាប់ផ្សេងៗ ត្រូវបញ្ចូលក្នុងថវិកាជាតិ ដើម្បីផ្តល់ផ្ទាល់ឲ្យទៅគណនីពិសេសនេះ ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ៦០.-**

សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងបទវិន័យ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។ បទវិន័យនេះ ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**មាត្រា ៦១.-**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបច្ចុប្បន្ន ត្រូវបន្តបំពេញការងាររហូតដល់មានប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលត្រូវបានតែងតាំងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ចូលកាន់មុខតំណែង ។

**មាត្រា ៦២.-**

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលត្រូវបង្កើតឡើងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ មានអាណត្តិរហូតដល់មានការតែងតាំងជាថ្មីនូវប្រធាន អនុប្រធាន និងសមាជិកគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ស្របតាមកថាខណ្ឌទី ៥ នៃមាត្រា ៦ នៃច្បាប់នេះ ។

**មាត្រា ៦៣.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលត្រូវបានបង្កើតឡើងស្របតាមបទប្បញ្ញត្តិ នៃច្បាប់នេះ ត្រូវបំពេញការងារ ដោយផ្អែកតាមច្បាប់ បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងលិខិតបទដ្ឋានដែលមានជាធរមានរហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស ។

**មាត្រា ៦៤.-**

អគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបន្តការងារជាអគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការ

បោះឆ្នោត ដែលបានរៀបចំឡើងតាមច្បាប់នេះ រហូតដល់មានការតែងតាំងថ្មី ស្របតាមច្បាប់នេះ ។

ការផ្លាស់ប្តូរ និងតែងតាំងអគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិក នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើឡើងដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មន្ត្រី បុគ្គលិកដែលកំពុងបម្រើការងារក្នុងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវបានធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌនៃលក្ខន្តិកៈដោយឡែក ដូចមានចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ៥៥ នៃច្បាប់នេះ ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ៦៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

**មាត្រា ៦៦.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥

ចរស.១៥០៣.២៣៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ២៥៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**